**Declassified to Public**
**12 June 2020**

លេខ៖ C1/1

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des Tribunaux cambodgiens

ការិយាល័យសហចៅក្រមស៊ើបអង្កេត

**Office of the Co-Investigating Judges**
**Bureau des co-juges d'instruction**

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 08 / 02 / 2016
ម៉ោង (Time/Heure): 11:08
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

**សំណុំរឿងលេខ៖ ០០៤/០៧-០៩-២០០៩-អ.វ.ត.ក -ក.ស.ច.ស**

ចំពោះមុខ ៖ **សហចៅក្រមស៊ើបអង្កេត**

កាលបរិច្ឆេទ ៖ **ថ្ងៃទី ៥ ខែ កុម្ភៈ ឆ្នាំ ២០១៦**

ភាសា ៖ **អង់គ្លេស/ខ្មែរ**

ចំណាត់ថ្នាក់ឯកសារ ៖ **សម្ងាត់**

# ដីកាសម្រេចលុបចោលដីកាបង្គាប់ឲ្យនាំខ្លួន អ៊ឹម ចែម

**ផ្ញើជូន៖**

**សហព្រះរាជអាជ្ញា**

ជា លាង

Nicholas KOUMJIAN

**មេធាវីការពារក្ដីអោ អាន**

មុំ លុជ្ស

Richard ROGERS
Göran SLUITER

**មេធាវីការពារក្ដីអ៊ឹម ចែម**

ប៊ិត ស៊ាងលឹម

John R.W.D. Jones

**មេធាវីការពារក្ដីយឹម ទិត្យ**

សូ មូស្សេនី

Suzana TOMANOVIĆ

**សហមេធាវីដើមបណ្ដឹងរដ្ឋប្បវេណី**

ជេត វណ្ណលី

ហុង គឹមសួន

គឹម ម៉េងឃី

ឡោ ជុនធី

សំ សុគង់

ស៊ិន ស៊ីវ៉ន

ទី ស្រ៊ីនណា

វ៉ែន ពៅ

Linda BEHNKE
Laure DESFORGES NZEPA
Herve DIAKIESE
Ferdinand DJAMMEN-NZEPA
Nicole DUMAS
Isabelle DURAND
Françoise GAUTRY
Emmanuel JACOMY
Martine JACQUIN
Christine MARTINEAU
Barnabe NEKUI
Lyma NGUYEN
Beini YE

## I. ប្រវត្តិនីតិវិធី

១. នៅថ្ងៃទី២៩ ខែ កក្កដា ឆ្នាំ ២០១៤ អតីតសហចៅក្រមស៊ើបអង្កេតអន្តរជាតិ Mark Harmon ("ស.ច.ស.អ Mark Harmon") បានចេញដីកាកោះហៅ អ៊ឹម ចែម ឲ្យចូលបង្ហាញខ្លួននៅ អ.វ.ត.ក សម្រាប់ការបង្ហាញខ្លួនលើកដំបូងនៅថ្ងៃទី ០៨ ខែ សីហា ឆ្នាំ ២០១៤[1]។ ដីកាកោះបានប្រគល់ជូន អ៊ឹម ចែម នៅថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ២០១៤[2]។

២. គាត់ បានខកខានមិនបានបង្ហាញខ្លួននៅ អ.វ.ត.ក ដោយគ្មានមូលហេតុ នៅក្នុងថ្ងៃដែលគាត់ត្រូវបានកោះឲ្យចូលខ្លួន។

៣. នៅថ្ងៃទី ១៤ ខែ សីហា ឆ្នាំ ២០១៤ ស.ច.ស.អ Mark Harmon បានចេញដីកាបង្គាប់ឲ្យនាំខ្លួន អ៊ឹម ចែម ("ដីកាបង្គាប់ឲ្យនាំខ្លួន") មកនៅចំពោះមុខ សម្រាប់ការបង្ហាញខ្លួនលើកដំបូង[3]។ រហូតមកដល់ថ្ងៃនេះ នគរបាលយុត្តិធម៌ មិនទាន់បានអនុវត្តដីកាបង្គាប់ឲ្យនាំខ្លួនទេ។

៤. ដោយហេតុនេះ អ៊ឹម ចែម ត្រូវបាន ស.ច.ស.អ Mark Harmon ដាក់ឲ្យស្ថិតក្រោមការពិនិត្យដោយកំបាំងមុខ នៅថ្ងៃទី៣ ខែមីនា ឆ្នាំ២០១៥[4]។ សេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍របស់ អ៊ឹម ចែម ចុះថ្ងៃទី ២ ខែ មេសា ឆ្នាំ២០១៥ ប្រឆាំងនឹងសេចក្តីសម្រេច ដាក់ស្ថិតក្រោមការពិនិត្យនោះ នៅមិនទាន់បានដោះស្រាយនៅឡើយ។[5]

៥. នៅថ្ងៃទី១៨ ខែធ្នូ ឆ្នាំ ២០១៥ ស.ច.ស បានជូនដំណឹងជាសាធារណៈទៅភាគីទាំងអស់ អំពីការបិទកិច្ចស៊ើបសួរប្រឆាំង អ៊ឹម ចែម[6] និង បានជូនដំណឹងជាសម្ងាត់ទៅភាគីទាំងអស់អំពី

---

[1]សំណុំរឿង០០៤ ឯកសារ A150 *ដីកាកោះហៅ អ៊ឹម ចែម ឲ្យបង្ហាញខ្លួនលើកដំបូង* ថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ២០១៤។ សំណុំរឿង០០៤ ឯកសារ A150/1 *កំណត់ហេតុនៃការប្រគល់ដីកាកោះ* ថ្ងៃទី ០៨ ខែ សីហា ឆ្នាំ ២០១៤។

[2]សំណុំរឿង០០៤ ឯកសារ A150/1 *កំណត់ហេតុនៃការប្រគល់ដីកាកោះ* ថ្ងៃទី ០៨ ខែ សីហា ឆ្នាំ ២០១៤។

[3]សំណុំរឿង០០៤ ឯកសារ C1 *ដីកាបង្គាប់ឲ្យនាំខ្លួន អ៊ឹម ចែម* ថ្ងៃទី ១៤ ខែ សីហា ឆ្នាំ ២០១៤។

[4]សំណុំរឿង០០៤ ឯកសារ D239 *ដីកាសម្រេចដាក់ អ៊ឹម ចែម ឲ្យស្ថិតក្រោមការពិនិត្យដោយកំបាំងមុខ* ថ្ងៃទី ៣ ខែ មីនា ឆ្នាំ ២០១៥។

[5]សំណុំរឿង០០៤ ឯកសារ D239/1/2 *បណ្តឹងឧទ្ធរណ៍របស់អ្នកស្រី អ៊ឹម ចែម ប្រឆាំងដីកា ស.ច.ស.អ សម្រេចដាក់អ្នកស្រី ឲ្យស្ថិតក្រោមការពិនិត្យដោយកំបាំងមុខ* ថ្ងៃទី ២ ខែ មេសា ឆ្នាំ ២០១៥។

[6]សំណុំរឿង០០៤ ឯកសារ D285 *សេចក្តីជូនដំណឹងអំពីការបិទកិច្ចស៊ើបសួរប្រឆាំង អ៊ឹម ចែម* ថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០១៥។

គោលបំណងរបស់ ស.ច.ស ចង់លើកលែងការចោទប្រកាន់ប្រឆាំង អ៊ឹម ចែម ដោយសារខ្វះយុត្តាធិការបុគ្គល[7]។

## II. ពិភាក្សា

៦. ឥឡូវនេះ កិច្ចស៊ើបសួរប្រឆាំង អ៊ឹម ចែម បានបញ្ចប់ហើយ។ ទោះបីជា សេចក្តីសម្រេចចុងក្រោយលើបញ្ហានេះ នឹងត្រូវធ្វើឡើងក្នុងដីកាដំណោះស្រាយ វាមិនមានភាពចាំបាច់សម្រាប់ អ៊ឹម ចែម ក្នុងការចូលរួមក្នុងនីតិវិធីជូនដំណឹងពីបទចោទប្រកាន់ទេ។

៧. ហេតុដូច្នេះ ដីកាបង្គាប់ឱ្យនាំខ្លួន លែងមានសុពលភាព ហើយត្រូវលុបចោល។

**តាមសំអាងហេតុខាងលើ យើង៖**

៨. **លុបចោល** ដីកាបង្គាប់ឱ្យនាំខ្លួន។

៩. **បង្គាប់** នគរបាលយុត្តិធម៌ ត្រូវបញ្ឈប់ការអនុវត្តដីកាបង្គាប់ឱ្យនាំខ្លួននេះ។

ភ្នំពេញ ថ្ងៃទី ៥ ខែ កុម្ភៈ ឆ្នាំ ២០១៦

**សហចៅក្រមស៊ើបអង្កេត**
Co-Investigating Judges
Co-juge d'instruction

**យូ ប៊ុនឡេង** Michael BOHLANDER

[7] សំណុំរឿង០០៤ ឯកសារ D286 *សេចក្តីជូនដំណឹងអំពីគោលបំណងលើកលែងការចោទប្រកាន់ប្រឆាំង អ៊ឹម ចែម និងបញ្ចប់កិច្ចដំណើរការនីតិវិធីប្រឆាំងគាត់* ថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០១៥។